ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៣៧៦ សហវ.ប្រក

ភ្នំពេញ ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១០

# ប្រកាស
## ស្តីពី
## ការធ្វើប្រតិភូកម្មសមត្ថកិច្ច និង សិទ្ធិសម្រេចពាក់ព័ន្ធនឹងកិច្ចលទ្ធកម្ម ក្នុងក្របខ័ណ្ឌគម្រោងហិរញ្ញប្បទានពីក្រៅប្រទេស

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៧ ស្តីពីការដាក់អោយប្រើប្រាស់នូវនីតិវិធីរួមសម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី

## សម្រេច

**ប្រការ១:** ប្រគល់សិទ្ធិចូលរួមជាតំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងកិច្ចលទ្ធកម្ម នៃគម្រោងហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ ក្នុងក្របខ័ណ្ឌនៃអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៧ ស្តីពីការដាក់អោយប្រើប្រាស់នូវនីតិវិធីរួមសម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី តាមកម្រិតដូចខាងក្រោម:

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

១- អគ្គលេខាធិការ ឬ អគ្គលេខាធិការរងទទួលបន្ទុកនាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការ ដឹកនាំការចូលរួម អមដោយមន្ត្រីពាក់ព័ន្ធក្រោមឱវាទ ចំពោះលទ្ធកម្មកម្រិតធំ (Major Procurements) ។ ក្នុងករណីមិនអាចចូលរួមដោយផ្ទាល់បាន អគ្គលេខាធិការ ឬអគ្គលេខាធិការរង មានសិទ្ធិចាត់មន្ត្រីពាក់ព័ន្ធក្រោមឱវាទ ឬមន្ត្រីក្រោមឱវាទផ្សេងទៀត ដឹកនាំការចូលរួមជំនួសបាន ។

២- ប្រធាននាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការដឹកនាំការចូលរួម ឬចាត់មន្ត្រីពាក់ព័ន្ធក្រោមឱវាទ ឬមន្ត្រីក្រោមឱវាទផ្សេងទៀត ដឹកនាំការចូលរួមជំនួស ចំពោះកិច្ចលទ្ធកម្មកម្រិតមធ្យម (General Procurements) ។

៣- ប្រធានការិយាល័យពាក់ព័ន្ធ នៃនាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការចូលរួម ឬអាចចាត់មន្ត្រីពាក់ព័ន្ធក្រោមឱវាទ ឬមន្ត្រីក្រោមឱវាទផ្សេងទៀត ចូលរួមចំពោះកិច្ចលទ្ធកម្មកម្រិតតូច (Minor Procurements) ។

**ប្រការ២:** អ្នកចូលរួមជាតំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងកិច្ចលទ្ធកម្ម ដូចមានចែងក្នុងប្រការ១ ខាងលើ មានសិទ្ធិពេញលេញក្នុងការសម្រេច ដោយមិនតម្រូវអោយសុំការសម្រេចជាមុនពីថ្នាក់លើតាមឋានានុក្រមទេ លើកលែងតែករណីដែលអ្នកចូលរួមយល់ថាមានវេទយិតភាព ។

**ប្រការ៣:** អគ្គលេខាធិការ ឬ អគ្គលេខាធិការរង ឬ មន្ត្រីពាក់ព័ន្ធក្រោមឱវាទ មានសិទ្ធិសម្រេចមិនចាត់តាំងសមាសភាពចូលរួមក្នុងកិច្ចលទ្ធកម្ម ក្នុងករណីយល់ថា ពុំមានភាពចាំបាច់អោយមានការចូលរួមពីតំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**ប្រការ៤:** អគ្គលេខាធិការ អគ្គលេខាធិការរង ប្រធាននាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការ ប្រធានការិយាល័យ និងមន្ត្រីពាក់ព័ន្ធ នៃនាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការ ត្រូវអនុវត្តប្រកាសនេះអោយមានប្រសិទ្ធភាព ។

**ប្រការ៥:** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

គាត ឈន់

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
- គ្រប់ក្រសួង ស្ថាប័ន

"ដើម្បីជូនជ្រាប"

- ដូចប្រការ៤ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ